បន្ទាប់ពីទទួលបានសារាចរនេះ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ត្រូវអនុវត្តខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និងអោយមានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## III- ការងារបណ្តាក្រសួង

### ១-ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០០

**ប្រកាសរួម លេខ ៦៩៦ ឧសក.រថ**

**របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស្តីពីការអនុវត្តនៃថ្លៃលក់អគ្គិសនីថ្មី សំរាប់ រាជធានីភ្នំពេញ និង ខេត្តកណ្តាល**

* * *

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រុមហ៊ុនអគ្គិសនីកម្ពុជា

-យោងលិខិតលេខ ១១០៥ សជណ.អក ចុះថ្ងៃទី ១០ កក្កដា ឆ្នាំ២០០០ ស្តីពីការសំរេចរបស់រាជរដ្ឋាភិបាលលើតារាងថ្លៃលក់អគ្គិសនីសំរាប់រាជធានីភ្នំពេញ និងខេត្តកណ្តាល

**សំរេច**

**ប្រការ ១ :** ប្រកាសអោយអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីសំរាប់រាជធានីភ្នំពេញ និងខេត្តកណ្តាល ដូចខាងក្រោម :

១-លំនៅដ្ឋានប្រជាជន មានថ្លៃលក់ ៣ប្រភេទ :

-បរិមាណទិញប្រចាំខែរហូតដល់ ៥០គីឡូវ៉ាត់ម៉ោង ថ្លៃ ៣៥០រៀល ១គីឡូវ៉ាត់ម៉ោង

-បរិមាណទិញប្រចាំខែ ចាប់ពី ៥១ គីឡូវ៉ាត់ម៉ោង ដល់ ១០០ គីឡូវ៉ាត់ម៉ោង ថ្លៃ ៥៥០រៀល ១គីឡូវ៉ាត់ម៉ោង និង

-បរិមាណទិញប្រចាំខែលើសពី ១០០គីឡូវ៉ាត់ម៉ោង ថ្លៃ ៦៥០រៀល ១គីឡូវ៉ាត់ម៉ោង

២-ស្ថាប័នរដ្ឋគ្រប់ប្រភេទ : មានថ្លៃលក់ ១ប្រភេទ គឺ ៧០០រៀល ១គីឡូវ៉ាត់ម៉ោង

៣-កន្លែងធ្វើការទាររបស់អង្គការក្រៅរដ្ឋាភិបាលបរទេស, លំនៅដ្ឋានជនបរទេស និងស្ថានទូតគ្រប់ប្រភេទ :

មានថ្លៃលក់ ១ប្រភេទ គឺ ៨០០រៀល ១គីឡូវ៉ាត់ម៉ោង

៤-កន្លែងធ្វើពាណិជ្ជកម្ម (សណ្ឋាគារ, ផ្ទះសំណាក់,ក្លឹបកំសាន្ត, កន្លែងលក់ទំនិញ,ធនាគារឯកជន, ការិយាល័យរបស់ក្រុមហ៊ុនឯកជន ។ល។ មានថ្លៃលក់ ៤ប្រភេទ :

-ពាណិជ្ជកម្មធុនតូច ថ្លៃ ៦៥០រៀល ១គីឡូវ៉ាត់ម៉ោង

-ពាណិជ្ជកម្មធុនមធ្យម ៦០០រៀល ១គីឡូវ៉ាត់ម៉ោង

-ពាណិជ្ជកម្មធុនធំ ៥០០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង និង

-ប្រភេទពាណិជ្ជកម្មប្រើប្រាស់លើតង់ស្យុងមធ្យម ៤៨០ រៀល ១គីឡូវ៉ាត់ម៉ោង ។

៥-ឧស្សាហកម្ម និង សិប្បកម្ម មានថ្លៃលក់ ៤ប្រភេទ :

-ឧស្សាហកម្មធុនតូច ៦០០រៀល ១គីឡូវ៉ាត់ម៉ោង

-ឧស្សាហកម្មធុនមធ្យម ៥៥០រៀល ១គីឡូវ៉ាត់ម៉ោង

-ឧស្សាហកម្មធុនធំ ៥០០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង និង

-ប្រភេទឧស្សាហកម្មប្រើប្រាស់លើតង់ ស្យុងមធ្យម ៤៨០ រៀល ១គីឡូវ៉ាត់ម៉ោង ។

ប្រការ ២ : មិនយកអាករលើតំលៃបន្ថែម លើថ្លៃលក់អគ្គិសនីក្នុងប្រការ១ខាងលើ ឡើយ ។

ប្រការ ៣ : ប្រភេទតូច, ប្រភេទមធ្យម, ប្រភេទធំ និងប្រភេទបន្តលើតង់ស្យុង មធ្យម សំរាប់អតិថិជន ពាណិជ្ជកម្ម (សណ្ឋាគារ,ផ្ទះសំណាក់,ក្លឹបកំសាន្ត,កន្លែងលក់ទំនិញ,ធនាគារឯកជន ,ការិយាល័យរបស់ក្រុមហ៊ុនឯកជន។ល។ និងអតិថិជន ឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

ប្រភេទតូច : អតិថិជនដែលបានភ្ជាប់ការប្រើប្រាស់ លើខ្សែបណ្តាញចែកចាយសាធារណៈ
តង់ស្យុងទាប ២២០ វ៉ុល ឬ ៣៨០ វ៉ុល

ប្រភេទមធ្យម : អតិថិជនដែលបានភ្ជាប់ការប្រើប្រាស់ពីបន្ទប់ភ្លើងផ្ទាល់ តាមទ្វារចេញតង់ស្យុងទាប
និងបានដាក់នាឡិកាស្ទង់នៅលើទ្វារចេញតង់ស្យុងទាបនោះ ។ អតិថិជនប្រភេទ
នេះមានលក្ខខណ្ឌប្រើប្រាស់ប្រចាំខែមិនតិចជាង ២០ ០០០ គីឡូវ៉ាត់ម៉ោង ។ ក្នុង
ករណីដែលការប្រើប្រាស់តិចជាងការកំណត់នេះ ត្រូវអនុវត្តតាមលក្ខខណ្ឌ នៃកិច្ច
សន្យាប្រើប្រាស់អគ្គិសនីរបស់អគ្គិសនីកម្ពុជា ។

ប្រភេទធំ : អតិថិជនដែលមានបន្ទប់ភ្លើងផ្ទាល់ខ្លួន ឬអតិថិជនដែលប្រើប្រាស់អនុភាពមួយ
ផ្នែកនៃបន្ទប់ភ្លើងសាធារណៈនិងមាននាឡិកាស្ទង់នៅក្នុង ឬជាប់បន្ទប់ភ្លើងដែល
ខ្លួនប្រើប្រាស់ ។ អតិថិជនប្រភេទនេះមានលក្ខខណ្ឌប្រើប្រាស់ប្រចាំខែមិន
តិចជាង ៥០ ០០០ គីឡូវ៉ាត់ម៉ោង ។ ក្នុងករណីដែលការប្រើប្រាស់តិចជាងការ

កំណត់នេះត្រូវអនុវត្តតាមលក្ខខ័ណ្ឌ នៃកិច្ចសន្យាប្រើប្រាស់អគ្គិសនីរបស់អគ្គិសនីកម្ពុជា ។

ប្រភេទតង់ស្យុងមធ្យម : អតិថិជនដែលបានភ្ជាប់ការប្រើប្រាស់លើខ្សែបណ្តាញតង់ស្យុងមធ្យម របស់ប្រព័ន្ធនិងបានដាក់នាឡិកាស្ទង់នៅផ្នែក តង់ស្យុងមធ្យម ។ អតិថិជនប្រភេទនេះមានលក្ខខ័ណ្ឌប្រើប្រាស់ប្រចាំខែមិនតិចជាង ៨០ ០០០ គីឡូវ៉ាត់ម៉ោង ។ ក្នុងករណីដែលការប្រើប្រាស់ទាបជាងការកំណត់នេះ ត្រូវអនុវត្តតាមលក្ខខ័ណ្ឌ នៃកិច្ចសន្យាប្រើប្រាស់អគ្គិសនីរបស់អគ្គិសនីកម្ពុជា ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចំពោះវិក័យប័ត្រអគ្គិសនីដែលចេញអោយអតិថិជន ចាប់ពី ថ្ងៃទី១ ខែ កញ្ញា ឆ្នាំ ២០០០ ទៅ និង លើចាមពលប្រើប្រាស់ចាប់ពីខែសីហា ឆ្នាំ ២០០០ តទៅ ។

ប្រការ ៥ : ប្រកាសនិងសេចក្តីសំរេច ដែលមានខ្លឹមសារផ្ទុយពីប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
ហត្ថលេខា និងត្រា
ស៊ុយ សែម

***

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៧៣៨ មស.ត្ររ
### ស្តីពីការកែតំរូវសេចក្តីសំរេច លេខ ១៥៦ សសរ មស.ត្ររ
### ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបែងចែកនិស្សិត ចំនួន ០៥នាក់
### ដែលទើបបញ្ចប់ការសិក្សាពីបរទេស

* * *

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១២៩៨.៨៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី